ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ ០០២១/១១ .រ.ស. គ.ស.ម

# សេចក្តីថ្លែងការណ៍

តំណាងរាស្ត្រ **គណបក្សសិទ្ធិមនុស្ស** មិនគាំទ្រការលើកអភ័យឯកសិទ្ធិសភារបស់ឯកឧត្តម **ចាន់ ចេង** សមាជិករដ្ឋសភាមណ្ឌលខេត្តកណ្តាល នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ នៅព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ ដោយតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំងអស់គ្នាបានដើរចេញពីអង្គប្រជុំរដ្ឋសភា ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា ការលើកអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រដោយងាយៗ ដោយមិនបានធ្វើការស៊ើបអង្កេត និងដោយគ្មានការពិភាក្សាពេលសម័យប្រជុំពេញអង្គ នាំឲ្យប៉ះពាល់ដល់កិត្យានុភាពរបស់ស្ថាប័ននីតិបញ្ញត្តិ ដែលជាស្ថាប័នកំពូល និងតំណាងឲ្យប្រជាជាតិខ្មែរទាំងមូល ។ មតិសាធារណជនអាចយល់ឃើញថា ស្ថាប័ននីតិបញ្ញត្តិនេះ គ្រាន់តែជាស្ថាប័នប្រថាប់ត្រា បម្រើឲ្យស្ថាប័ននីតិប្រតិបត្តិតែប៉ុណ្ណោះ ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា រដ្ឋសភាត្រូវបង្កើតគណៈកម្មការពិសេសដែលមានសមាសភាពចូលរួមពីគ្រប់គណបក្សនយោបាយដែលមានអាសនៈនៅរដ្ឋសភា ដើម្បីធ្វើការតាមដានស្រាវជ្រាវឲ្យបានច្បាស់លាស់ រួចធ្វើរបាយការណ៍ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ មុននឹងសម្រេចដាក់ក្នុងរបៀបវារៈនៃការលើកអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រនីមួយៗ និងសម័យប្រជុំពេញអង្គរដ្ឋសភាត្រូវផ្តល់ឱកាសឲ្យមានការពិភាក្សាយ៉ាងទូលំទូលាយ ដើម្បីអនុញ្ញាតឲ្យសាមីខ្លួន ឬតំណាងរបស់សាមីខ្លួន អាចបញ្ចេញមតិការពារខ្លួនផង ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១

| សមាជិករដ្ឋសភា | សមាជិករដ្ឋសភា | សមាជិករដ្ឋសភា |
|---|---|---|
| កឹម សុខា | យ៉ែម បុញ្ញឫទ្ធិ | អ៊ូ ច័ន្ទឫទ្ធិ |
| តំណាងរាស្ត្រមណ្ឌលកំពង់ចាម | តំណាងរាស្ត្រមណ្ឌលព្រៃវែង | តំណាងរាស្ត្រមណ្ឌលកណ្តាល |

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*
*ទូរស័ព្ទលេខ ៖ 016 435 106*